ក្រសួងអប់រំ យុវជន និង កីឡា

# ៥ រូបភាព

# បញ្ឈប់ពលកម្មកុមារ

## ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

## វត្ថុបំណង:

-បង្កើតជាឯកសាររបស់កុមារពលកម្ម ។
បង្កើតនិងពង្រីកឯកសារ ។
-រៀបចំជាបរិបទដែលកុមារពលកម្មរស់នៅដោយ
ធ្វើអោយស្ថិតនៅក្នុងបរិបទពិភពលោកដ៏ធំទូលាយ ។





## លទ្ធផលរំពឹងទុក :

ធ្វើអោយបញ្ហាកុមារពលកម្មក្លាយជាលក្ខណៈផ្ទាល់ខ្លួន
និងពង្រីងនូវការយល់ដឹងអំពីអ្វីដែលហៅថា "**កុមារពលកម្ម**" ។
-បណ្តុះគំនិតទទួលខុសត្រូវសំរាប់កុមារដោយធ្វើជារូបភាព
-ណែនាំអំពីសំណួរពីរបៀបដែលនាំអោយមានការផ្លាស់ប្តូរ
នៅក្នុងសង្គម ។

## ការកំណត់ពេលវេលា

*បង្រៀន ៤ពេល( ម្តង២ពេលជាប់គ្នា ឬដាច់ពីគ្នា*

## ហេតុផល

ប្រសិនបើបានបញ្ចប់ម៉ូឌុលនេះហើយ(Collagemodule) អ្នកត្រូវបង្ហាញដល់ក្រុមរបស់អ្នកថា តើវាមានភាពងាយស្រួលប៉ុណ្ណាដែលពិភពលោកធ្វើការព្រងើយកន្តើយចំពោះពលកម្មកុមារ ហើយធ្វើហាក់ដូចជាបញ្ហាពលកម្មកុមារ មិនមានកើតឡើងសោះ ។ តាមរយៈការធ្វើដូចនេះអ្នកត្រូវបង្កើតជាគំនិតរំពឹងទុកមួយនៅក្នុងសមាជិកក្រុមរបស់អ្នក គឺជាតម្រូវការចាំបាច់ ។ ពួកគេនឹងនិយាយទៅកាន់ខ្លួនរបស់ពួកគេថា "**ត្រឹមត្រូវហើយ**" ពលកម្មកុមារពិត ជាកើតមានមែនក៏ប៉ុន្តែពួកយើងមិនបានដឹងថា មានលក្ខណៈដូចម្តេច ពី



### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ប្រសិនបើអ្នកបង្រៀនម៉ូឌុលទាំងនេះ ជារបៀបដែលមានលក្ខណៈជាប្រព័ន្ធនោះ យើងសូមផ្តល់យោបល់ ដល់អ្នកសូមអ្នក អនុវត្តម៉ូឌុលអំពីគំនូរនេះជាមុនសិន មុននឹងដោះស្រាយបញ្ហានេះ ។ ផ្ទាំងគំនូរក៏ប្រើប្រាស់រូបភាពជាច្រើនផងដែរ ដើម្បីបញ្ជូនសារនឹង ដែលប្រកបដោយលក្ខណៈបែបសាមញ្ញ ។ វានឹងកាន់តែអាចជួយច្រើនថែមទៀត ប្រសិន បើក្រុមរបស់ អ្នកដឹងពីស្ថិតិជាមូលដ្ឋាន និង ពត៌មានស្តីពីកុមារពលកម្ម (ដែល មាននៅ ក្នុងម៉ូឌុលដែលនិយាយពីព័ត៌មានជាមូលដ្ឋាន) ហើយពួកគេបានឆ្លង កាត់រួចរាល់នូវលំហាត់ ដែលបង្កើត ការយល់ដឹង ។



ព្រោះថា បញ្ហាទាំងនេះមិនមាននៅក្នុងទស្សនាវដ្តី និងសារព័ត៌មានណាមួយនោះទេ។ ហេតុដូច្នេះតើពលកម្មកុមារ មានលក្ខណៈយ៉ាងដូចម្តេច? ម៉ូឌុលនេះនឹងបង្ហាញ មុខមាត់ពលកម្មកុមារ។

វត្ថុបំណងនៃសកម្មភាពទីមួយនៅក្នុងម៉ូឌុលនេះ គឺសំរបសំរួល និងបង្ហាញរូបភាពកុមារពលកម្ម។ វាអាចមានករណីជាច្រើននៃពលកម្មកុមារនៅក្នុងបរិយាកាសដែលអ្នកកំពុងតែរស់នៅហើយ អ្នកអាចនាំក្រុមរបស់អ្នកអោយទៅជួបកុមារពលកម្មទាំងនេះដោយផ្ទាល់ខ្លួនរបស់ពួកគេ សមាជិកខ្លះនៅក្នុងក្រុមរបស់អ្នកអាចធ្លាប់មានបទពិសោធន៍ ចំពោះពលកម្មកុមារ ឬបានដឹងពីកុមារដែលមានបទពិសោធន៍ ចំពោះពលកម្មកុមារនោះ អាចចែករំលែកបទពិសោធន៍របស់គេបាន។ នៅក្នុងប្រទេសខ្លះ អ្នកប្រហែលជាមិនអាចមានជំរើសបែបនេះឡើយ ហើយហេតុដូច្នេះ អ្នកនឹងត្រូវការរូបភាពមួយជារូបក្រាហ្វិករបស់កុមារម្នាក់កំពុងធ្វើការ ហើយដែលក្រុមអ្នកអាចមើលឃើញ និងអាចផ្តល់ជីវិតអោយវា ។

លំហាត់នេះនិងធ្វើឱ្យក្រុមរបស់អ្នកប្រឹងគិតអំពីអ្វីដែលជាកុមារពលកម្មពិតប្រាកដនោះ។ លំហាត់នេះនឹងផ្លាស់ប្តូរពួកគេ។ វត្ថុបំណងនៃលំហាត់សំខាន់ណាស់សំរាប់ពួកគេ គឺដើម្បីអោយពួកគេយល់នឹងដឹងអោយកាន់តែច្រើនឡើងថែមទៀត អំពីកុមារពលកម្ម។ គេត្រូវចាប់ផ្តើមធ្វើការងារនេះជាមួយអារម្មណ៏របស់មនុស្សវ័យក្មេង ហើយចាប់ផ្តើមធ្វើយ៉ាងណា អោយពួកគេមានកំហឹងចំពោះពលកម្មកុមារ។ នឹងពិបាកដើរចេញពីលំហាត់ដោយមិនបានទទួល អារម្មណ៏ជាបទពិសោធន៍ណាមួយនោះ។

សកម្មភាពទី២ នឹងឈានមួយជំហ៊ានទៅមុខទៀត ក្នុងការបង្កើតបរិយាកាសកាន់តែទូលំទូលាយចំពោះអ្វីដែលកុមាររស់នៅនិងធ្វើការងារ។ ហើយសកម្មភាពនេះវាក៏ចាប់ផ្តើមបង្កើតជាប្រវត្តិសាស្ត្រ និងអនាគតកាលរស់របស់កុមារ។ ហើយនៅទីបំផុតសកម្មភាពនេះ នឹងនាំឱ្យមើលពីបញ្ហាផ្លាស់ប្តូរសំខាន់ៗ និងថាតើគេនាំអោយមានការផ្លាស់ប្តូរយ៉ាង ដូចម្តេច។

ប្រហែលជាមនុស្សវ័យក្មេងនៅក្នុងក្រុមមានបទពិសោធន៍ធ្វើ

ការងារសង្គមមួយចំនួនខ្លះៗហើយ ដូចជាស្ម័គ្រចិត្តក្នុងការការពារពលរដ្ឋ ឬកម្មវិធីកាកបាទ ឬ អឌ្ឍច័ន្ទក្រហម ការថែរក្សាមនុស្សចាស់ជរា ឬ ជួយកុមារដែលគេបោះបង់ចោល។ គ្រប់ផ្នែកនៃការងារស្ម័គ្រចិត្តទាំងនេះ គឺមានស្ថានភាពផ្ទៃរឿងជាទូទៅមួយ គឺពួកគេធ្វើអោយមានការពាក់ព័ន្ធ គ្នាជាមួយអ្នកដែលងាយរងគ្រោះជាជនជាតិភាគតិច ឬជនដែលរស់នៅ តំបន់ដាច់ស្រយាល អ្នកដែលគេបោះបង់ចោល ឬ អ្នកដែលគេវាយធ្វើបាបក្នុងករិតណាមួយ ឬផ្សេងៗទៀត។ លើសពីនេះទៅទៀតសកម្មភាពស្ម័គ្រចិត្តទាំងនេះបានចង្អុលបង្ហាញពីតំរូវការសំរាប់គ្រប់សមាជិកសង្គមទាំងអស់ គឺត្រូវតែចូលរួមចំណែកក្នុងការផ្សព្វផ្សាយអោយមានការផ្លាស់ប្តូរ។

ម៉ូឌុលនេះក៏បានណែនាំផងដែរចំពោះបច្ចេកទេសនៃការប្រមូលគំនិតដែលវា គឺជាវិធីសាស្រ្តដ៏មានប្រយោជន៍ដែលអាចអនុញ្ញាតិអោយបុគ្គលម្នាក់ៗអាចសំដែងចេញនូវអារម្មណ៍ និងគំនិតផ្សេងៗ គ្នាដោយស្ថិតនៅបរិយាកាសដែលមិនមានការគំរាមគំហែង។ ការប្រមូលគំនិត គឺផ្តល់ឱកាសអោយមានការសំដែងចេញនូវអារម្មណ៍ ដែលគេជាធម្មតាតែងលាក់វាទុកការប្រមូលគំនិតវា គឺជាឧបករណ៍ជួយជំរុញម្យ៉ាងហើយវា និង ជួយអោយមានការតាំងចិត្តកាន់តែខ្លាំងៗឡើងថែមទៀតរបស់មនុស្សវ័យក្មេងដើម្បីលុបបំបាត់នូវពលកម្មកុមារ។

## អ្វីដែលអ្នកត្រូវការ



- ✓ រូបថតមួយសន្លឹក ឬ រូបភាពដែលបោះពុម្ពចេញពីកុំព្យូទ័រ ដែលជារូបភាពកុមារពលកម្ម ។
- ✓ បន្ទប់មួយសំរាប់ធ្វើការងារជាក្រុម ។ប្រសិនបើអ្នកមានក្រុមពិភាក្សាចំនួនច្រើនអ្នកត្រូវតែបំបែកក្រុមនេះអោយទៅជាក្រុមតូចៗ ហើយបែងចែកបន្ទប់ជាកន្លែងទំនេរតូចៗល្មម ។
- ✓ ជញ្ជាំងដែលគ្មានរូបភាព ដើម្បីបិទផ្ទាំងរូបភាព ឬ រូបភាពប្រសិនបើអ្នកមានរូបភាពចំនួន១ ឬ ច្រើន ២ផ្ទាំង ។
- ✓ ក្រដាស និងប៊ិច/ខ្មៅដៃសំរាប់សមាជិកក្រុមធ្វើការកត់ចំណាំ ។
- ✓ ប្រសិនបើអាច គេត្រូវមានក្តាខៀនសរសេរហ្វឺត/សរសេរដីសរ ឬផ្ទាំងរូបដែលអាចបើកបង្ហាញ " flipchart "



## ការរៀបចំ

ក្នុងការរៀបចំកិច្ចតែងការ អ្នកចាំបាច់ត្រូវតែជ្រើសរើសរូបភាពពលកម្មកុមារមួយ ឬ ពីរ បីសន្លឹក ហើយអ្នក ត្រូវប្រាកដថាអ្នកអាចថតចំលងវាអោយបានគ្រប់គ្រាន់ ដើម្បីចែកដល់ក្រុមពិភាក្សា (សូមអ្នកកុំបារម្ភប្រសិនបើអ្នកមិនមានម៉ាស៊ីនថតចំលង) ។ អ្នកអាចប្រើរូបភាពថតចំលងដែលមាននៅក្នុងកញ្ចប់មេរៀនចំនួនមួយសន្លឹកក៍អ្នកអាចដំណើរមេរៀនក្នុងម៉ូឌុលនេះបានដែរ ។ នៅក្នុងកញ្ចប់មេរៀន នេះអ្នកនឹងឃើញរូបភាពពលកម្មកុមារ ។របៀបម្យ៉ាងទៀតដែលអ្នក ធ្វើបានគឺអ្នកអាចស្រាវជ្រាវរករូបភាពផ្សេងៗទៀតដោយប្រើប្រាស់ ប្រភពមួយ ឬ មួយចំនួនខាងក្រោម :



- ប្រសិនបើអ្នកអាចប្រើប្រាស់កុំព្យូទ័រ និងអ៊ិនធឺណេតបាននោះ សូមអ្នកចូលទៅបើកគេហទំព័ររបស់ IPEC Web site ([www.ilo.org/public/english/standards/ipec/index.htm](www.ilo.org/public/english/standards/ipec/index.htm)) ដែលមានរូបភាពជាច្រើនស្តីពីកុមារពលកម្ម នៅក្នុងប្រអប់រូបភាព (gallery) ។ ចូរអ្នកមើលអោយសព្វក្នុងប្រអប់ រូបភាពនេះ ហើយស្វែងរករូបភាពណាមួយដែលសមស្របទៅនឹងតម្រូវការរបស់



**កំណត់សម្គាល់សំរាប់អ្នកប្រើប្រាស់**

អង្គការ IPEC បានផលិតនូវរូបភាពកាតូឡុកជា CD-ROM ដែលអ្នកអាចឃើញវានៅខាងក្នុងគំរបនៃម៉ូឌុលនេះ ដែលមានចំណងជើងថា "អនុស្សាវរណៈ និងសេចក្តីប្រកាសអន្តរជាតិ និងរូបភាពកុមារពលកម្ម" ឬអាចស្នើសុំដោយផ្ទាល់មកកាន់ការិយាល័យ IPEC ។ សូមអ្នកបំពេញនូវព័ត៌មានលំអិត ហើយបញ្ជូនមកតាមអស័យដ្ឋានទាក់ទងរបស់ IPEC ដើម្បីស្នើសុំថតចំលង CD-ROM ឬស្នើសុំរូបភាពថតចំលងដែលបោះពុម្ពចេញរួច ។



អ្នក ហើយអ្នកអាចថតចំលងវាចេញពីអ៊ិនធឺណេត ឬថតចំលងវាចូលទៅក្នុងម៉ាស៊ីនកុំព្យូទ័ររបស់អ្នក ហើយបោះពុម្ពវាចេញមកដោយប្រើកម្មវិធីរូបភាពរបស់កុំព្យូទ័រ ។ វាកាន់តែប្រសើរខ្លាំងណាស់ ប្រសិនបើអ្នកមានម៉ាស៊ីនបោះពុម្ពជាពណ៌ធម្មជាតិ ។ តែប្រសិនបើមិនមានរូបភាពសខ្មៅក៏បានដែរ ។ ចូរអ្នកថតចំលងវាអោយបានគ្រប់គ្រាន់សំរាប់ក្រុមពិភាក្សា ។

- អង្គការ ILO ក៏មានផ្ទាំងរូបភាព កុមារពលកម្មផងដែរ ហើយគេអាចប្រើផ្ទាំងរូបភាពនេះសម្រាប់ជាប្រយោជន៍នៃការបង្រៀនដែរ ។ អង្គការដទៃទៀតផ្សេងៗដូចជា UNESCO UNICEF ឬ ជំនួយដើម្បីអាចទទួលបានរូបភាពថតចំលង ។

សមាសភាគ (Element) ដែលត្រូវពិចារណានៅពេលជ្រើសរើសរូបភាព គឺ :

- ពិចារណាលើបញ្ហាយេនឌ័រ អាយុ និងការបញ្ចូលវប្បធម៌ចំរុះរបស់មនុស្សវ័យក្មេង ដែលបង្កើតជាក្រុម ។ ការធ្វើដូចនេះនឹងជួយអ្នកក្នុងការជ្រើសរើសនូវរូបភាព ដែលសក្តិសមបំផុតសម្រាប់ពួកគេ ។ ជាឧទាហរណ៍ តើអ្នកនឹងស្វែងរករូបក្មេងប្រុស ឬក្មេងស្រីនៅក្នុងតំបន់អាហ្វ្រិក តំបន់អាស៊ី តំបន់អាមេរិកឡាទីន ឬតំបន់អឺរ៉ុប? តើអ្នកស្វែងរករូបភាពដែលមានទម្រង់អាក្រក់នៃពលកម្មកុមារឬ? អាចពិចារណាយករូបភាពខុសៗគ្នាជាច្រើនហើយប្រើប្រាស់វានៅក្នុងកាលៈទេសៈខុសៗគ្នា ។
- ជ្រើសរើសរូបភាពដែលមានលក្ខណៈលំអិត និងមានគុណភាពសមរម្យ ។ ការជ្រើសរើសបែបនេះនឹងជួយមនុស្សវ័យក្មេងកំណត់នូវកុមារពលកម្ម នូវអ្វីដែលគេធ្វើ និងទីកន្លែងដែលពួកគេមកហើយ នឹងជួយពួកគេប្រមូល បង្កើតរូបភាពដោយផ្ទាល់ខ្លួនរបស់ពួកគេ ។ ការធ្វើបែបនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ។

- អ្នកត្រូវតែប្រាកដថា អ្នកមានក្រដាស និងខ្មៅដៃគ្រប់គ្រាន់សម្រាប់ពេលដែលសមាជិកក្រុមចង់សរសេរ និងកត់ត្រាលំហាត់នេះ។ ប្រសិនបើអាច គេគួរប្រើផ្ទាំងរូបភាពបត់ចុះឡើង ឬ ក្តារខៀនសរសេរដីសរ/ហ្វឺត ព្រោះសំភារៈទាំងនេះនឹងត្រូវគេប្រើច្រើនក្នុងកំឡុងពេលពិភាក្សា។
- ប្រសិនបើសម្ភារទាំងនេះ មានការលំបាករក ចូរអ្នកអោយមនុស្សវ័យក្មេងនៅក្នុងក្រុមរបស់អ្នកយកសម្ភារៈពីផ្ទះរបស់ពួកគេ ឬ ពីទីកន្លែងដែលពួកគេរស់នៅ ពីរោងចក្រផលិតរបស់ចាស់ឡើងវិញ ពីសប្បុរសជននៅតាមមូលដ្ឋាន ឬ កន្លែងជំនួញផ្សេងៗទៀត។ ការធ្វើអោយពួកគេមានការពាក់ព័ន្ធបែបនេះ អាចធ្វើអោយពួកគេអភិវឌ្ឍន៍នូវគំនិតភាពជាម្ចាស់ការចំណាប់អារម្មណ៍ និងការលើកទឹកចិត្ត។ ការចង់ដឹងយ៉ាងខ្លាំងពីធម្មជាតិរបស់ ពួកគេនឹងធ្វើអោយពួកគេដឹងថា អ្វីដែលពពួកគេត្រូវការចាំបាច់សំរាប់ទាំងនេះ។

# ការចាប់ផ្តើម



ផ្នែកទីមួយនៃលំហាត់នេះគឺធ្វើអោយចេះបង្កើតនូវប្រវត្តិរបស់កុមារពលកម្មដោយផ្អែកលើមូលដ្ឋានរូបភាព។ រូបភាព គឺជាចំនុចចាប់ផ្តើម ហើយដែលក្រុមត្រូវបង្កើតដោយមានជំនួយពីការនឹកស្រមៃនិងការច្នៃប្រឌិតរបស់ពួកគេនៅពេលដែលពួកគេបង្កើតនូវសំណុំឯកសារប្រវត្តិរបស់ពួកគេ ហើយពួកគេនឹងធ្វើការបង្ហាញសុំណុំឯកសារប្រវត្តិនេះទៅកាន់ក្រុមដទៃផ្សេងទៀត ដើម្បីឱ្យឆ្លើយសំណួរ និងចូលរួមពិភាក្សាជាទូទៅមួយ។ មានការផ្លាស់ប្តូររូបពីរយ៉ាង ហើយចេញពីការផ្លាស់ប្តូររូបនេះ អ្នកអាចជ្រើសរើសសម្រាប់សកម្មភាពនៃលំហាត់។ អាចប្រើរូបភាពតែមួយសម្រាប់ពិភាក្សាទាំងអស់ ដើម្បីឱ្យក្រុមពិភាក្សាទាំងនោះអាចប្រៀបធៀបការងាររបស់ពួកគេ និងស្តាប់ហើយរៀនពីសុំណុំឯកសារប្រវត្តិរបស់ក្រុមនីមួយៗ អ្នកអាចផ្តល់រូបភាពពលកម្មកុមារមួយសន្លឹកខុសៗគ្នាទៅឱ្យក្រុមនីមួយៗ ដើម្បីឱ្យអ្នកជំរុញក្រុម ឱ្យធ្វើការងារផ្សេងៗគ្នា ហើយអាចឱ្យមនុស្សវ័យក្មេងនៅក្នុងក្រុមយល់ច្បាស់ថា ពលកម្មកុមារមានរូបរាងនិងទម្រង់ជាច្រើនប្រភេទ។ អ្នកអាចជ្រើសរើសវិធីណាមួយខាងលើក៏បាន វាអាស្រ័យលើក្រុមពិភាក្សារបស់អ្នកធ្វើបាន ឬមិនបាន។

## ការរៀបចំក្រុម

អ្នកអាចរក្សាក្រុមពិភាក្សារបស់អ្នកឱ្យនៅជុំគ្នាទាំងអស់ ឬ បំបែកពួកគេឱ្យទៅជាក្រុមតូចៗដែលមានសមាជិកមិនលើសពីចំនួន៤ ឬ ៥នាក់។ ការធ្វើបែបនេះ គឺអាស្រ័យលើទំហំក្រុម ពិភាក្សារបស់អ្នកដែរ។ ហើយចូរអ្នកប្រាកដថាក្រុមនីមួយៗ មានរូបភាពថតចំលងមួយឬ មានមើលរូបភាពរួចរាល់ហើយ។ មូលហេតុ ដែលការធ្វើការងារជាក្រុមមានភាពប្រសើរជាងការធ្វើការងារតែម្នាក់ឯងនោះគឺ ដោយសារតែមនុស្សវ័យក្មេងមានជំនឿជាក់លើខ្លួនរបស់គេ នៅពេលនៅជាមួយគ្នាច្រើន។ ពួកគេប្រហែលជាមិនមានភាពងាយស្រួលទេ ក្នុងការព្យាយាមរៀបចំសំណុំឯកសារ ប្រវត្តិប្រឌិត មួយអំពីកុមារពលកម្មដោយខ្លួនគេម្នាក់ឯងផ្ទាល់នោះ។ នៅពេលដែលពួកគេស្ថិតនៅ ក្នុងក្រុមដែលមានគ្នាចាប់ពីចំនួន២ ទៅ ៤ ឬ ៥ នាក់ នោះ ពួកគេតែងតែមានអារម្មណ៍ធូរស្បើយ។



## សកម្មភាព១ ៖
## ការរៀបចំចងក្រងឯកសារប្រវត្តិរបស់កុមារពលកម្មម្នាក់

*បង្រៀន១ពេលឬ២ពេលដាច់ពីគ្នា*

ឱ្យសមាជិកក្រុមចែករូបភាពឱ្យក្រុមរបស់ពួកគេមើល។ ប្រសិនបើអ្នកមិនមានរូបថតចំលងគ្រប់គ្រាន់ចែកឱ្យក្រុមនីមួយៗបានគ្រប់ៗគ្នាទេ ចូរអ្នកចែកឱ្យសមាជិកក្រុមពិភាក្សាទាំងអស់មើលម្នាក់ម្តងៗ ហើយបន្ទាប់មកបិទរូបភាពនោះជាប់នៅជញ្ជាំង ដើម្បីឱ្យពួកគេមើល និងឱ្យគេមើលដោយយកចិត្តទុកដាក់ក្នុងកំឡុងពេលដែលពួកគេធ្វើលំហាត់នេះ។ ករណីដែលក្រុមនីមួយៗ មានរូបភាពគ្រប់ៗគ្នា ចូរអ្នកប្រាប់ពួកគេឱ្យចែកគ្នាមើល ហើយបន្ទាប់ពីមើលចប់ ឱ្យពួកគេដាក់រូបភាពនៅកណ្តាលក្រុមរបស់គេ ដើម្បីឱ្យអ្នកគ្រប់គ្នាក្នុងក្រុមអាចមើលឃើញទាំងអស់គ្នា។ អ្នកត្រូវដើរមើលតាមក្រុមនីមួយៗយឺតៗ ហើយជំរុញពួកគេឱ្យសិក្សាពីរូបភាពដោយយកចិត្តទុកដាក់ ហើយព្យាយាមគិតអំពីប្រធានបទសម្រាប់កុមារ នៅក្នុងរូបភាព។ ហើយចូរអ្នកប្រាប់ពួកគេឱ្យធ្វើទៅតាមការស្រមៃឃើញរបស់ពួកគេនិងតាមគំនិតច្នៃប្រឌិតដែលគេអាចនឹកឃើញចេញមក។

**កសាងគោលការណ៍ជាមូលដ្ឋាន**



មានពីរដំណាក់កាលក្នុងផ្នែកនៃលំហាត់នេះ ៖

ដំហានដំបូងគឺត្រូវនាំឱ្យក្រុមពិភាក្សាទាំងអស់គិតថា តើកុមារនោះជានរណា? ហើយតើកុមារនោះរស់នៅ និងធ្វើការក្នុង បរិស្ថានប្រភេទបែបណា? មានសំណួរជាច្រើនដែលក្រុមត្រូវសួរខ្លួនរបស់គេផ្ទាល់។ អ្នកអាចសរសេរសំណួរខ្លះៗទាំងនេះនៅលើក្តារខៀន ឬនៅកន្លែងណាមួយ ហើយអានសំណួរ ឬមួយក៏អាចថតចំលងសំណួរទាំងនោះហើយចែកឱ្យក្រុមពិភាក្សា ប៉ុន្តែពេលអ្នកសរសេរ ដើម្បីថតចំលងនោះ សូមអ្នកទុកចន្លោះផង ដើម្បីឱ្យក្រុមនីមួយៗគេ អាចបន្ថែមសំណួររបស់ពួកគេនៅលើក្រដាសថតចំលងនោះផងដែរ។ ប្រសិនបើអ្នកផ្តល់សំណួរដែលមានលក្ខណៈលំអិតខ្លាំងពេកនោះ អ្នកមិនបានជួយពួកគេអោយប្រើការគិតច្រើននោះទេ តែអ្នកធ្វើឱ្យពួកគេមានការធុញថប់ ហើយខ្ជិលទៅវិញទេ។

ចូរអ្នកលើកទឹកចិត្តក្រុមពិភាក្សាទាំងអស់ បង្កើតជាប្រធានបទសម្រាប់ការរៀបចំសុំណុំឯកសារប្រវត្តិរបស់កុមារដោយផ្អែកលើសំណួរជាមូលដ្ឋានដូចខាងក្រោម :

- តើកុមារនោះជាកុមារី ឬ កុមារា?
- តើអ្នកគិតថា កុមារនោះមានអាយុប៉ុន្មាន ?
- តើកុមារនោះ មកពីណាដែរ បើតាមអ្នកគិត?
- តើហេតុអ្វីបានជាកុមារត្រូវបានគេបំពាក់ឧបករណ៍ ឬ គេឱ្យស្លៀកពាក់បែបនោះ?
- តើវាកុមារនោះធ្វើការស្ថិតក្នុងស្ថានភាពបែបណា?
- តើនេះ គឺជាតំបន់ជនបទ ឬ តំបន់ទីក្រុង ( ប្រជុំជន ) ?

ក្រុមខ្លះអាចចាប់ផ្តើមដំណើររឿងសំណុំឯកសារជាទំរង់ពិពណ៌នាជាកំណត់ចំណាំ ឬ ជាចំនុចគំនិតគោល១។ ហើយក្រុមដទៃផ្សេងទៀតអាចផ្តើមបង្កើតជារូបភាពរបស់ប្រធានបទនៅក្នុងខួរក្បាលរបស់ពួកគេ ឬ ជាទំរង់រូបភាពលំអិតដោយមានគូររូបភាព ដទៃផ្សេងទៀតនៅជុំវិញ។ ទោះជាពួកគេជ្រើសរើសបង្កើតសុំណុំឯកសារតាមរបៀបណាក៏ដោយក៏អាចទទួលយកបានដែរ។ ចូរអ្នកបន្តនិយាយជាមួយពួកគេឱ្យជាប់ក្នុងកំឡុងពេលធ្វើលំហាត់ពោលគឺកុំឱ្យចំណាប់អារម្មណ៍របស់ពួកគេខ្សោយ។ នៅពេលដែលពួកគេធ្វើការជាមួយបញ្ជីសំណួរដែលដាក់ឱ្យខាងលើហើយ អ្នកឃើញថាពួកគេធ្វើការបានល្អឆ្លើយទៅនឹងសំណួរទាំងនោះ ចូរអ្នកបន្តឱ្យមានការបង្កើតសំណួរផ្ទាល់ខ្លួនបន្ថែមទៀត ហើយចាប់ផ្តើមធ្វើការសិក្សាលើប្រធានបទកាន់តែស៊ីជំរៅទៅ :

- តើកុមារនោះមានឈ្មោះអ្វី?
- តើកុមារនេះ ធ្វើការអស់រយៈពេលប៉ុន្មានហើយ ?
- តើកុមារនេះមានឪពុកម្តាយ បងប្អូនប្រុសស្រីសត្វចិញ្ចឹមឬទេ?
- តើស្ថានភាពសេដ្ឋកិច្ច ឬ សង្គមរបស់កុមារនេះយ៉ាងដូចម្តេច?

## ព័ត៌មានបន្ថែម





- តើហេតុអ្វីបានកុមារធ្វើការទាំងអស់ ?
- តើភេទរបស់កុមារមានជះឥទ្ធិពលលើប្រភេទដែលកុមារនោះធ្វើដែរឬទេ?
- តើកុមារនេះត្រូវគេវាយដំ បោះបង់ចោលវាយរំលោភសេពសន្ថវៈ ជួញដូរផ្លូវភេទ ឬ ត្រូវបានគេយកចិត្តទុកដាក់ថែរក្សាឬទេ?
- តើមិត្ត ឬ សត្រូវបែបណាខ្លះ ដែលកុមារមាននៅកន្លែងធ្វើការ និងក្រៅកន្លែងធ្វើការ?
- តើកុមារចូលចិត្តធ្វើអ្វី នាពេលបច្ចុប្បន្នជំនួសការងារនោះ?
- តើកុមារមានមហិច្ឆិតាណាមួយនៅក្នុងជីវិតដែលមិនមានពាក់ព័ន្ធទៅនឹងការងាររបស់គេដែរឬទេ ? តើអ្វីទៅដែលជាមហិច្ឆិតាធំបំផុតរបស់កុមារនៅក្នុងជីវិត?
- ប្រសិនបើមានអ្វីមួយ តើកុមារមានអ្វីជារបស់ខ្លួន? ហើយតើត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីឱ្យគេមានរបស់ទាំងនោះ ?
- តើអ្វីទៅជាការចងចាំដ៏ល្អបំផុត និងអាក្រក់បំផុតរបស់កុមារ?

អ្នកនិងសួរអ្នកមើលរូបភាពទាំងនោះឱ្យមានភាពស្រមើស្រមៃនិងភាពច្នៃប្រឌិត ពួកគេអាចនិយាយថា "តើគេឱ្យយើងស្គាល់ឈ្មោះរបស់កុមារទាំងនោះយ៉ាងដូចម្តេច? ក្មេងទាំងនេះប្រហែលជានិយាយភាសាខុសៗគ្នា។ ហើយតើយើងដឹងថាពួកគេមានតុក្កតាដោយរបៀបណា? " នោះគឺជាចំនុចទាំងមូលនៃលំហាត់នេះ។ ពួកគេមិនបានដឹងអ្វីទាំងអស់ក្រៅមើលឃើញរូបរាងកុមារនោះតាមរូបភាពប៉ុណ្ណោះ។ ពួកគេត្រូវតែដាក់សាច់ទៅលើគំរោងឆ្អឹង គឺធ្វើឱ្យមានជីវិតមានអតីតកាលនិងមានគ្រួសារ។

នេះគឺជាលទ្ធផលដែលអ្នកកំពុងស្វែងរក នៅពេលដែលអ្នក ចូលពិនិត្យមើលក្រុមពិភាក្សា ចូរអ្នកពិនិត្យមើលភាពរីកចំរើនរបស់ពួកគេ។ ស្តាប់ការពិភាក្សារបស់ពួកគេ ហើយអ្នកបន្ថែមអ្វីជាគំនិតរបស់អ្នក ហើយនិងលើកទឹកចិត្តពួកគេអោយមានភាពកំប្លែង។ ឱ្យពួកគេដឹងថា ពួកគេអាចបង្កើតជាសំណុំឯកសារក្នុងទម្រង់ណាក៏ដោយ ដែលគេចង់ធ្វើហើយសូមឱ្យពួកគេគួរតែព្យាយាមបង្កើតដោយ គំនិតច្នៃប្រឌិត និងស្របើស្រមៃតាមតែអាចធ្វើទៅបានក្នុងការបញ្ចេញនូវទស្សនៈរបស់ពួកគេ ចំពោះសំណុំឯកសារនេះទៅកាន់ក្រុមពិភាក្សាពេញអង្គ។ ជាឧទាហរណ៍ពួកគេអាចឡើងបង្ហាញសំណុំឯកសារជាទម្រង់រូបភាព ឬក៏រៀបចំជាការពណ៌នាលំអិតនៅលើក្តារខៀន សរសេរហ្វីត /ជីស ឬផ្ទាំងរូបភាពដែលអាចបង្ហាញបាន។

## ការបង្ហាញពីប្រវត្តិ



ចូរអ្នកកុំពន្យារពេល អ្នកគួរតែអនុញ្ញាតិ (តែ ២០នាទី ជាការគ្រប់គ្រាន់ហើយ)។ ព្យាយាមដាក់សំពាធលើពួកគេ ឱ្យបញ្ចប់សំណុំឯកសាររបស់ពួកគេ ហើយនៅពេលដែលអ្នកឃើញថាដល់ពេលហើយនោះ ហៅអ្នកទាំងអស់គ្នាមកជួបជុំពិភាក្សាទូទៅមួយ។ ក្រុមពិភាក្សាទាំងអស់ត្រូវការពិភាក្សាអំពី "តួអង្គ" ដែលគេបង្កើតឡើងនេះ។ អ្នកត្រូវរៀបចំម៉ោងសម្រាប់ការបង្ហាញឱ្យមានសភាពរស់រវើក ហើយប្រកបដោយបរិយាកាសរីករាយដែលក្រុមនីមួយៗអាចចែករំលែកបទពិសោធន៍អំពីសំណុំឯកសារកុមារពលកម្ម "របស់ពួកគេ" ជាមួយនិងអ្នក ព្រមទាំងក្រុមដទៃផ្សេងទៀត។

ប្រសិនបើក្រុមខ្លះមានបញ្ហាក្នុងការរៀបចំបង្ហាញការងាររបស់ពួកគេទុកពេលឱ្យគេរៀបចំអោយបានរួចរាល់ដោយលើកយកចំនុចសំខាន់ៗ។ ការបង្ហាញទាំងនោះ (ប្រសិនបើមិនមែនជាករណីកើតឡើងជានិច្ចកាល) ផ្តល់នូវបរិយាកាសធូរស្រាល និងមានលក្ខណៈជាធម្មជាតិមួយដ៏ល្អរវាងអ្នកស្តាប់ និងអ្នកបង្ហាញ។ ចូរអ្នកអនុញ្ញាតិពេលឱ្យពួកគេក៏ប៉ុន្តែកុំឱ្យពួកគេព្យាយាមអូសបន្លាយការបង្ហាញឱ្យកាន់តែវែងអន្លាយ។

ប្រសិនបើអ្នកមានអារម្មណ៍ថា វាសមរម្យល្មមហើយ និងមានភាពច្នៃប្រឌិតរបស់ក្រុមហើយនោះ អ្នកគួរតែណែនាំជាការប្រកួតប្រជែងមួយ ឧទាហរណ៍ដូចជា :

- ផ្តល់រង្វាន់សម្រាប់សំណុំឯកសារកុមារពលកម្ម ដែលមានលក្ខណៈពណ៌នាលំអិតបំផុត។ ឱ្យក្រុមទាំងអស់ជាអ្នកកាត់ក្តីសម្រាប់ការប្រកួតនេះ។
- ផ្តល់រង្វាន់សំរាប់ការបង្ហាញដែលមានលក្ខណៈដើមទាំងស្រុងនៃសំណុំឯកសាររបស់កុមារពលកម្ម។

ចូរអ្នកសរសេរតួអង្គនៅក្នុងសំណុំឯកសារផ្សេងៗនៅលើក្តារខៀនសរសេរហ្វឺត/ដីសរឬ នៅលើផ្ទាំងរូបភាព។

ប្រសិនបើអ្នកធ្វើការដោយ ឱ្យក្រុមពិភាក្សាលើរូបភាពដូចគ្នា អ្នកត្រូវធ្វើជាសំណុំឯកសារកុមារពលកម្មជារួមមួយ ដោយដកស្រង់

ចេញពីក្រុមមួយៗ។ ចូរអ្នកធ្វើឱ្យពួកគេឃើញថា ពួកគេបានចូលរួមចំណែកផ្តល់រូបភាពនេះឱ្យមានជីវិតទាំងអស់គ្នា។ ប្រធានបទនេះមានជីវិតចេះដកដង្ហើមបានដើរ បាននិយាយបានចេះមានអារម្មណ៍។ ចេះសើចនិងយំ។



នេះគឺជាជំហានមួយដ៏មានសារៈសំខាន់បំផុតក្នុងដំណើរការបង្កើនការយល់ដឹងជាមួយមនុស្សវ័យក្មេង។ ដោយពួកគេអាចមានលទ្ធភាពតភ្ជាប់អារម្មណ៍ជាមួយរូបភាពកុមារ ពលកម្មនេះ។ រូបភាពមួយៗនេះគឺជារូបភាពរបស់គេម្នាក់ៗក្នុងចំណោមពួកគេ។ ហើយដែលម្នាក់នេះគឺគេជាសមាជិកនៃក្រុមដែលមានអាយុស្មើរគ្នារបស់ពួកគេជាមិត្តភក្តិ ឬ ជានរណាដែលពួកគេគិតដល់។ ពេលធ្វើដូចនេះពួកគេនិងអាចចាប់ផ្តើមយល់ពីការឈឺចាប់វេទនា និងការខ្វះខាតដែលកុមារនេះទទួលការឈឺចាប់ជាប្រចាំថ្ងៃ។ វាគឺជាដំណើរកានៃឧបមាវិធីមួយដ៏មានប្រសិទ្ធិភាពដែលអាចឱ្យមនុស្សវ័យក្មេងមានកិរិតយល់ដឹងថ្មីមួយ គ្មានអ្វីដែលមានសភាពដូចគ្នាសម្រាប់ពួកគេឡើយ។

នេះគឺជាភាសាពិភាក្សាដែលអ្នកច្របាច់បញ្ចូលគ្នាអោយទៅជាការសន្និដ្ឋានដ៏សាមញ្ញមួយ។ ចូរអ្នកប្រើប្រាស់បច្ចេកទេសទំនាក់ទំនងដែលមានភាពស្និទ្ធិស្នាល។ ចូរអ្នកសំលឹងមើលភ្នែករបស់ពួកគេដែលជាអ្នកស្តាប់នៅពេលដែលអ្នកពណ៌នាពីជីវិតដែលពួកគេបង្កើតឡើងសម្រាប់កុមារពលកម្ម។ ចូរអ្នកបង្ហាញអោយឃើញអ្វីៗ ដែលស្តែងចេញពីអារម្មណ៍ពិតៗ។ ចូរអ្នកអានបណ្តើរដើរតាមក្រុមនីមួយៗយឺតៗ និងប្រើប្រាស់ភាសា កាយវិការ ដើម្បីបង្ហាញពីការឈឺចាប់។ នេះគឺជាផ្នែកដែលមានភាពស្រយុងចិត្តក៏ប៉ុន្តែវា គឺជាការរំជួលចិត្តរបស់កុមារពលកម្មតាមបែបធម្មជាតិរបស់វា ពិតប្រាកដណាស់ វាអាចបំផ្លិចបំផ្លាញជីវិតរបស់ពួកគេ និងប្លន់នូវសិទ្ធិមនុស្សដ៏សែនមានតំលៃ គឺសិទ្ធិមានសេរីភាព។

## សកម្មភាព២ : ការបង្កើតបរិបទ

*បង្រៀនមួយពេល*



កុមារពលកម្មមិនត្រូវរស់នៅធ្វើជាអ្នកបោសសំអាតផ្ទះ និងម៉ាស៊ីនបោសផ្ទះនោះទេ។ ហើយពួកគេក៏មិនត្រូវតែយកទៅដាក់នៅលើកោះដាច់ស្រយាលនៅកណ្តាលសមុទ្រដីសែនខ្មៅ ប្រកបដោយក្តីឈឺចាប់ និងក្តីវេទនាដែរ។ ពួកគេទាំងអស់គ្នាមាននៅក្នុង"**ទីនេះ និងពេលឥឡូវនេះ**" ។ គឺពួកគេរស់នៅក្នុងប្រទេសជិតខាងយើង រដ្ឋក្បែរយើង គឺអាចនិយាយថាពួកគេអាចរស់នៅកាច់ជ្រុងនៃផ្ទះរបស់យើង ឬនៅក្បែរផ្ទះរបស់យើង។ ជាការពួកយើងចាំបាច់ផ្តើមដាក់កុមារពលកម្មចូលទៅក្នុងបរិបទដែលជាបរិបទពិភពលោកបរិបទបរិស្ថានសង្គម និងសកលភាវូបនីកម្មភូមិរបស់ពួកយើង។

នៅពេលដែលពួកគេបានទទួលស្គាល់នូវការពិតនៃពលកម្មកុមារហើយនោះ មនុស្សវ័យក្មេងក៏ទទួលស្គាល់ផងដែរនូវតំរូវការចាំបាច់សំរាប់អោយមានការផ្លាស់ប្តូរ និងសំរាប់អ្នករាល់គ្នាដែលខឹងសម្បារចំពោះស្ថានភាពដែលបានឃើញហើយចង់និងទាមទារ អោយផ្លាស់ប្តូរស្ថានភាពនេះ។

# តើអ្វីទៅជាការប្រមូលគំនិត ?



ការប្រមូលគំនិត គឺជាការពិភាក្សាអំពីគំនិតដែលមានលក្ខណៈទូលំទូលាយតាមរយៈកិច្ចប្រឹងប្រែងខាងផ្នែកប្រាជ្ញាធ្វើជាឧបករណ៍រិះគិត ដោយស្ថិតនៅក្រោមសំពាធមួយ។ សំពាធនេះត្រូវបានគេបង្កើតឡើង ដោយកំណត់ពេលវេលាជាក់លាក់មួយ ឬការកំណត់ផ្សេងទៀត តាមចិត្តសាស្ត្រ និងកាយវិការ។ ភាពតានតឹងនេះ នឹងបង្កើតនៅលើកំលាំងចិត្តរបស់មនុស្សជាតិ និងកំលាំងរាងកាយដែលបានចូលរួមយ៉ាងច្រើនលើសលប់ ហើយជានិច្ចកាលមិនបានរាំងខ្ទប់នៅក្នុងការឆ្លើយនៃកំលាំងទាំងនេះបានឡើង។ នៅក្នុងករណីភាគីច្រើនលំហាត់នេះនឹងចំរាញ់អោយមានការ ប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកមានលក្ខណៈជាអារម្មណ៏និងភាពស្មោះត្រង់។ ការប្រាស្រ័យទាក់ទងគ្នានេះនឹងជាអ្វីដែលមាននៅក្នុងដួងចិត្ត ហើយដែលជាញឹកញាប់ជួយបំភ្លឺ និងឱ្យចាត់ចែងបានប្រសើរ ហើយលំហាត់នេះគឺ ពិតជាបានជួយយ៉ាងច្រើន។

ការប្រមូលគំនិត គឺជាលំហាត់ដែលមានការពាក់ព័ន្ធគ្នាយ៉ាងខ្លាំង។ ដូចដែលបាននិយាយខាងលើរួចហើយ ការប្រមូលគំនិតអាចនាំឱ្យមានបរិយាកាសសប្បាយ និងដ៏សែនមានប្រយោជន៏ ព្រមទាំងការលាតត្រដាងនូវរាល់គំនិតនានា។ តែជាយ៉ាងណាក៏ដោយ ប្រសិនបើមិនបានរៀបចំ និងធ្វើផែនការឱ្យបានត្រឹមត្រូវវានឹងក្លាយជាមានភាពរញ៉េរញ៉ៃ ហើយប្រែក្លាយពីល្អទៅជាអាក្រក់ភ្លាមមួយរំពេចដោយធ្លាក់ចូលទៅក្នុងការប្រកួតប្រជែងគ្នាដែលស្រែកគំហកតឹងសរសៃកដាក់គ្នាទៅវិញទៅមក។ ប្រសិនបើមនុស្សវ័យក្មេងយល់ច្បាស់ពីការទាំងនេះ អ្នកមិនចាំបាច់ត្រួតត្រាទាំងស្រុងនោះ ដោយគ្រាន់តែអ្នកសំរបសំរួលនូវការពិភាក្សាអំពីការ គិតប្រមូលគំនិតនោះបានឡើយ។ យុទ្ធសាស្ត្រមូលដ្ឋាននៃការប្រមូលគំនិត គឺត្រូវស្ថិតនៅក៏រិតកំពូលនៃគំនិត ពោលគឺត្រូវការកត់ត្រានូវរាល់គំនិត ដែលនឹកឃើញហើយត្រូវរក្សាល្បឿនការងារអោយមធ្យម។ សមាជិកម្នាក់ៗនៅក្នុងក្រុមត្រូវតែ គិតទៅតាមជំហានការងារដែលមានម៉ោង កំណត់ហើយមិនត្រូវប្រើវេលាយូរក្នុងការគិតនោះទេ និងមិនត្រូវមាន ភាពលំបាកក្នុងការបញ្ចេញអំពីគំនិតរបស់ខ្លួនឡើយ។

## ការកំណត់ភារកិច្ច

អ្នកត្រូវតែប្រាកដថា ក្រុមដែលអ្នករៀបចំត្រូវបានបង្កើតឡើង ដោយមានចំនួនសមាជិកដូចគ្នាសម្រាប់ សកម្មភាពមួយហើយឱ្យទៅពួកគេនូវរូបភាពមួយដូចគ្នារបស់កុមារពលកម្មដែលពួកគេធ្លាប់មានពីមុនមក។

ចូរអ្នកចំណាយពេលប្រមាណ១០នាទី សម្រាប់រំលឹកនូវសកម្មភាពទី១ ដែលបានបង្កើតសំណុំឯកសារកុមារពលកម្មមុននឹងអ្នកចាប់ផ្តើមបន្តមេរៀនស្តីពីសំណុំឯកសារកុមារពលកម្ម។ នេះជាផ្នែកមួយនៃការអប់រំ និងការបង្ហាញបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ដូច្នេះវាសំខាន់ខ្លាំងណាស់ដែលគេត្រូវដាក់ឈ្មោះឱ្យរូបភាពដែលគេប្រើ។ វាក៏មានសារៈសំខាន់ផងដែរ ចំពោះអ្នកផ្ទាល់ការប្រើឈ្មោះទាំងនេះ នៅពេលដែលមនុស្សវ័យក្មេងឆ្លើយតបចំពោះសកម្មភាពនេះ។ ប្រសិនបើអ្នកទទួលយកភាពផ្ទាល់ខ្លួន និងតួអង្គដែលពួកគេបានបង្កើត អ្នកនឹងធ្វើឱ្យចំរើននូវទំនាក់ទំនង នៃការជឿទុកចិត្ត។

ជំហានបន្ទាប់នៃលំហាត់នេះ គឺត្រូវពិចារណានូវអ្វីដែលអាចកើតមានឡើង ហើយដែលអាចប៉ះពាល់ដល់ជីវិតរបស់កុមារពលកម្ម។ អ្នកត្រូវស្នើឱ្យក្រុមពិភាក្សាពិចារណាលើការផ្លាស់ ប្តូរដែលបានកើតឡើងនៅក៏រិតមូលដ្ឋានជាតិ តំបន់ និងអន្តរជាតិ និងថាតើព្រឹត្តិការណ៍ ទាំងនេះបានជះឥទ្ធិពលដល់ជីវិតរស់នៅរបស់កុមារនៅក្នុងរូបភាពយ៉ាងដូចម្តេច?

ដើម្បីការងារខាងលើនេះ អ្នកត្រូវតែបង្កើតឱ្យមានបរិយាកាសសប្បាយរីករាយអោយមានសកម្មភាពប្រមូលគំនិត ដោយមានការគិតក្នុងរយៈពេលខ្លី។ គោលគំនិតនេះ គឺចង់ជំរុញឱ្យអ្នកស្តាប់គិតពិចារណាលើអ្វីដែលជាឥទ្ធិពលដែលនាំឱ្យមានការផ្លាស់ប្តូរនៅជុំវិញពិភពលោកចំពោះការរស់នៅរបស់កុមារពលកម្មថា តើការផ្លាស់ទាំងនោះវាល្អអាក្រក់ ឬត្រូវគេមិនអើពើ។

## ផលប៉ះពាល់នៃការផ្លាស់ប្តូរ



អាស្រ័យហេតុនេះហើយ ជំហានបន្ទាប់នេះបានក្រុមពិភាក្សាឱ្យធ្វើពុតជាគិតថា រូបភាពនេះត្រូវបានយកមកមួយពីរ ឬពាន្នាំកន្លងមកហើយ។ បន្ទាប់មកពួកគេគួរតែគិតអំពីព្រឹត្តិការណ៍សំខាន់ដែលបានកើតឡើងជុំវិញពិភពលោក ចាប់តាំងពីរូបភាពនេះត្រូវបានយកមកដោយឱ្យពួកគេពិចារណាថា តើមានផលប៉ះពាល់អ្វី (ប្រសិនបើមាន) ចំពោះព្រឹត្តិការណ៍ទាំងនេះដែលបានកើតមានចំពោះកុមារពលកម្មនៅក្នុងរូបភាព។ ការធ្វើបែបនេះគឺមាននៅក្នុងរបៀបពីរយ៉ាង :

- ពួកគេអាចកត់ត្រានៅឡើងក្រដាសនូវអ្វីៗទាំងអស់ដែលបានកើតឡើងក្នុងគំរោងពេលវេលា ។
- អ្នកអាចឱ្យពួកគេប្រាប់ពីព្រឹត្តការណ៍ផ្សេងៗដែលបានកើតឡើង ហើយត្រូវយកព្រឹត្តការណ៍ មួយរបស់ពួកគេដែលបានឆ្លើយ ហើយយកមកគិត និងសរសេរជាព័ត៌មាននៅលើក្តារខៀន សរសេរហ្វឹត ដីស ផ្ទាំងរូបភាព ឬនៅលើឯកសារអ្វីក៏បានដែលអ្នកត្រូវប្រគល់ឱ្យពួកគេ។ ជំរើសនេះគឺហាក់ដូចជាមានភាពរស់រវើក និងភាពសប្បាយច្រើនចំពោះមនុស្សវ័យក្មេង ហើយវាពិតជាអាចទាក់ទាញការចាប់អារម្មណ៍របស់ពួកគេច្រើនឡើង។ ពន្យល់ទៅក្រុមនោះថាព្រឹត្តិការណ៍ដែលយើងនឹកឃើញមាន ដូចជា : ព្រឹត្តិការណ៍កីឡា សង្គ្រាមស៊ីវិល បាតុកម្ម កុប្បកម្ម ការទស្សនកិច្ចរបស់បុគ្គលសំខាន់មហន្តរាយដែលកើតឡើងដោយធម្មជាតិ ឬដោយសារមនុស្សជាអ្នកបង្កើតការស្លាប់របស់បុគ្គលដ៏ សំខាន់ៗមានជាច្រើនទៀតឥតគណនា។

បន្តការពិភាក្សាឱ្យមានភាពរស់រវើក ស្ថិតក្នុងពេលវេលាកំណត់មួយរវាង ៥ ទៅ ១០នាទី។ ធ្វើឱ្យអ្នករាល់គ្នាពាក់ព័ន្ធដោយបង្កើតភាពកំប្លែងខ្លះ ដោយអ្នកផ្ទាល់បង្កើតជាសំណួរបែបកំប្លែង។ ហើយឱ្យពួកគេមានយោបល់ខ្លះៗ ទៅលើអ្វីដែលមនុស្សវ័យក្មេងទាំង នេះមិនបានគិតដល់ឧទាហរណ៍ដូចជាសង្គ្រាមការផ្លាស់ប្តូរ



រដ្ឋាភិបាល សន្និសីទអន្តរជាតិ សំខាន់ជាដើម ។

នៅពេលដែលអ្នកយល់ឃើញថា អ្នករាល់គ្នាចាប់ផ្តើម ហើយនោះ អ្នកគួរតែសរុបនូវការប្រមូលគំនិតនេះ ដោយឱ្យអ្នករាល់គ្នាមើលតារាង ព្រឹត្តិការណ៍ ដែលសរសេរចេញពីក្រុមពិភាក្សាទាំងអស់ ។ បន្ទាប់មកអ្នកត្រូវតែបើកការពិភាក្សាជារួមមួយដោយជជែកអំពីព្រឹត្តិការណ៍ទាំងនោះ ហើយសួរពួកគេថា តើព្រឹត្តិការណ៍ទាំងនោះមានឥទ្ធិពលអ្វីលើជីវិតរបស់កុមារពលកម្មនៅក្នុងរូបភាពនេះទេ ។ ចូរអ្នកសួរពួកគេនូវសំណួរដូចខាងក្រោម :



- តើព្រឹត្តិការណ៍ណាមួយនៃព្រឹត្តិការណ៍ទាំងនេះបានជះឥទ្ធិពលល្អ អាក្រក់ ឬគ្មានអើពើលើជីវិតកុមារពលកម្មដែរឬទេ? បើជះ តើជះឥទ្ធិពលជារបៀបណា?
- តើអ្នកគិតថា ក្មេងនៅក្នុងរូបភាពនេះ កំពុងតែធ្វើអ្វីឥឡូវនេះនៅពេលដែលពួកគេមានអាយុ ៣ឆ្នាំ ?
- តើជីវិតក្មេងក្នុងរូបភាពមានការប្រែប្រួលរបៀបណាមួយដែរឬទេអំឡុងពេល ៣ឆ្នាំនេះ?
- តើក្មេងនេះនៅមានជីវិតនៅឡើយឬ?
- តើក្មេងកំពុងតែធ្វើការនៅឡើយឬ?
- តើក្មេងកំពុងតែលេងជាមួយមិត្តភក្តិ ឬនៅផ្ទះជាមួយ និងគ្រួសាររបស់គេឬទេ?

លើកទឹកចិត្តពួកគេឱ្យមានការផ្លាស់ប្តូរបទពិសោធន៍ជុំវិញសំណួរទាំងនេះ ហើយត្រូវជួយគេក្នុងកំឡុងពេលពិភាក្សា ប្រសិនបើអ្នកត្រូវបន្តទៅជាជំហានណាមួយទៀត ។ នៅពេលដែលមានភាពរីកចំរើននៃការពិភាក្សាក្រុម ពិភាក្សាត្រូវចាប់ផ្តើមយល់នូវស្ថានភាពដាច់ដោយឡែករបស់កុមារពលកម្ម ហើយក៏ត្រូវយល់ថា មានការផ្លាស់ប្តូរដ៏តិចតួចណាស់នៅលើស្ថានភាពកុមារដ៏អភ័ព្វទាំងនេះ ។ ពួកគេធ្វើការងារ និងអត់ធនចំពោះការងារធ្ងន់ៗដោយមានក្តីសង្ឃឹមថានឹងមានអនាគតដ៏ប្រសើរមួយ តែពេលខ្លះក្តីសង្ឃឹមរបស់គេត្រូវរលត់

## ប្រយុទ្ធដើម្បីផ្លាស់ប្តូរ



ទាំងអាយុរបស់គេនៅវ័យក្មេងម្ល៉េះមនុស្សវ័យក្មេងដែលនៅក្នុងក្រុម ត្រូវដឹងថាគេចាំបាច់ត្រូវជះឥទ្ធិពល ដើម្បីឱ្យមានការផ្លាស់ប្តូរ ។

នៅពេលដែលអ្នកមានអារម្មណ៍ធុញទ្រាន់នឹងសកម្មភាពនេះ អ្នកត្រូវរំកិលទៅកាន់សកម្មភាពបន្ទាប់ ។

នេះគឺជាលំហាត់ចុងក្រោយនៃមេរៀនក្នុងម៉ូឌុលនេះ ។ សម្រាប់សកម្មភាពនេះក៏ត្រូវអនុវត្តនីជាទំរង់បែប សកម្មភាពប្រមូលគំនិតដែរ ។ គោលបំណងនៅក្នុងសកម្មភាពលំហាត់ចុងក្រោយនេះគឺ ចង់លើកទឹកចិត្តឱ្យក្រុម ពិភាក្សាទាំងអស់គិតពីអ្វីដែលកើតមានឡើង ហើយដែលអាចផ្លាស់ប្តូរនូវជីវិតរបស់កុមារពលកម្មដែលមាននៅក្នុងរូបភាព ។ សួរពួកគេនូវសំណួរដូចខាងក្រោម :

- តើអ្វីទៅដែលមនុស្សណាម្នាក់ អាចធ្វើឱ្យជីវិតកុមារពលកម្មមានការផ្លាស់ប្តូរ មានភាពខុសប្លែកគ្នា និងរបៀបផ្សេងគ្នានោះ?
- តើមានអ្វីដែលក្រុមពិភាក្សាអាចធ្វើបានហើយ ដែលនាំឱ្យជីវិតរបស់កុមារពលកម្មមានការផ្លាស់ប្តូរ?
- តើការផ្លាស់ប្តូរពិតប្រាកដ កើតឡើងយ៉ាងដូចម្តេចនៅក្នុងពិភពលោក?
- តើការផ្លាស់ប្តូរយ៉ាងដូចម្តេច ដែលកើតឡើងនៅក្នុងក្រុមដែលអាយុស្របាលគ្នា នៃមនុស្សវ័យក្មេងនៅក្នុងបន្ទប់នេះ?
- តើក្រុមពិភាក្សា ឬសមាជិកក្នុងក្រុមគិតថាវាមានសារៈសំខាន់ទេ ដែលកាលណាមានការប្រែប្រួលឡើង? ហេតុអ្វី?

ដោយប្រើវិធីដូចពេលមុន ត្រូវលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរយោបល់មានសកម្មភាពរស់រវើកសំរាប់ រយៈពេលពី ៥ ទៅ ១០នាទី ក៏ប៉ុន្តែសម្រាប់សកម្មភាពនេះ អ្នកត្រូវតែធ្វើជាប្រធានក្រុម និងធ្វើជាអ្នកកត់ត្រានៅលើក្តារខៀន ឬផ្ទាំងរូបភាព ។ ចូរអ្នកធ្វើអន្តរាគមន៍ឆ្លើយតបឱ្យបានឆាប់រហ័សតាមតែអាចធ្វើបាន ។ ប្រសិនបើអ្នកឱ្យក្រុមពិភាក្សាអស់ពេលវេលាយូរក្នុងការគិត ពួកគេអាចមានការស្ទាក់ស្ទើរក្នុងការចូលរួមយោបល់ក្នុងក្រុម ព្រោះពួកគេអាចមានអារម្មណ៍ថា ការឆ្លើយតប ឬយោបល់របស់គេមិនគ្រប់គ្រាន់ ។ អ្នកនឹងឃើញថាការប្រើម៉ោងរៀនដោយប្រើការប្រមូលគំនិត ដែលជាការគិតលើកដំបូងរបស់មនុស្ស ជាពិសេសមនុស្សវ័យក្មេងអាចផ្តល់នូវគំនិត ដែលផុសចេញពីចិត្តចូលទៅក្នុងប្រធានបទ និងហាក់ដូចជាមានគំនិតភ្លឺថ្លា ចូលរួមក្នុងការពិភាក្សា ។

នៅពេលដែលគេចាប់ផ្តើមការពិភាក្សា អ្នកត្រូវប្រាកដថាពួកគេមិនប្រើការពិភាក្សាអូសបន្លាយរយៈពេលវែងនោះទេ ។ ចូរអ្នកធ្វើការសង្ខេបនូវកំណត់ត្រាផ្ទាល់ខ្លួនរបស់អ្នកទៅលើការពិភាក្សានោះ ហើយទទួលយកចំលើយ តបមកវិញពីក្រុមពិភាក្សា ។

## អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ



- ចូរអ្នកលើកទឹកចិត្តឱ្យក្រុមពិភាក្សាទាំងអស់ឱ្យស្រមើស្រមៃទៅតាមអ្វីដែលពួកគេប្រាថ្នានៅពេលបង្កើតសំណុំឯកសារស្តីពីកុមារពលកម្ម។ សមាជិកក្រុមខ្លះអាចព្យាយាមធ្វើការលេង១ ដើម្បីកំណត់នូវលំហាត់ក៏ប៉ុន្តែសំណាងដែលគេនៅក្នុងក្រុមអាយុស្របាលគ្នា។ គេអាចដើរតួយ៉ាងសំខាន់ដែរនៅទីនេះជាមួយក្រុមដែលយកចិត្តទុកដាក់ហើយក្របដណ្តប់ទៅលើសមាជិកមួយចំនួនដែលធ្វើការឡេះឡោះ។ ហើយចុងបញ្ចប់ពួកគេទាំងអស់គ្នា និងហ្មត់ចត់ចំពោះលំហាត់នេះ។



- ចូរអ្នកកុំធ្វើជាសំណាកគំរូ ជាកុមារពលកម្ម និងមនុស្សវ័យក្មេងនៅក្នុងក្រុមរបស់អ្នក។ ជាឧទាហរណ៍ ចូរអ្នកកុំបែងចែកប្រុសម្ខាង និងស្រីម្ខាងនៅក្នុងក្រុមពិភាក្សា ហើយបន្ទាប់មកផ្តល់រូបភាពរបស់ក្មេងប្រុសដែលកំពុងតែធ្វើការងារទៅក្រុមក្មេងប្រុស និងរូបភាពក្មេងស្រី កំពុងតែធ្វើការងារផ្ទះទៅក្រុមក្មេងស្រី។ នេះគឺជាជំហានមួយ ដែលស្ថិតក្នុងទិសដៅដែលខុសឆ្គង។ លើកទឹកចិត្តឱ្យមានការច្របាច់ចូលគ្នារវាងក្មេងប្រុស និងក្មេងស្រី ហើយព្យាយាមស្វែងរករូបភាពដែលបង្ហាញថាក្មេងស្រី ជាញឹកញាប់ធ្វើការងារធ្ងន់ធ្ងររួមទាំងការងារប្រើកំលាំងកាយ ហើយពេលខ្លះបុរសវ័យក្មេង១បានបង្ខំក្មេងស្រីឱ្យធ្លាក់ខ្លួនក្លាយជាស្ត្រីពេស្យាចារក្នុងប្រទេសមួយចំនួន។
- ចូរអ្នកកុំផ្តល់សំណួរច្រើនពេកសម្រាប់ក្រុមពិភាក្សាឱ្យស្វែងរកចំលើយ។ លើកទឹកចិត្តពួកគេឱ្យគិតពីសំណួរដោយខ្លួនរបស់គេផ្ទាល់។ ពួកគេអាចនឹកឃើញនូវគំនិតដើមគ្រប់ប្រភេទ។ ការធ្វើបែបនេះគឺពិតល្អណាស់ ព្រោះវាគឺជាសញ្ញាមួយដ៏ច្បាស់លាស់ ដែលមានការពាក់ព័ន្ធ និងចំណាប់អារម្មណ៍របស់ពួកគេចំពោះការពិភាក្សា។
- ចូរអ្នកលើកទឹកចិត្តឱ្យសមាជិកនៃក្រុមពិភាក្សាទាំងអស់ឱ្យចូលរួម និងមានការពាក់ព័ន្ធយ៉ាងសកម្ម នៅក្នុងលំហាត់។

- ចូរលើកទឹកចិត្តឱ្យចូលរួមដោយមិនដឹងខ្លួននៅក្នុងម៉ោងរៀនធ្វើការប្រមូលគំនិត។ ចូរអ្នកព្យាយាមធ្វើឱ្យពួកគេមានចិត្តជ្រះថ្លា និងភាពកំប្លែង បើអាចធ្វើទៅបាន។ មេរៀនដែលរៀនទាំងនេះ គឺធ្វើការ "សង្កត់ធ្ងន់" លើចិត្តសាស្ត្រ និងអារម្មណ៍សំរាប់មនុស្សវ័យក្មេង។ ពួកក្មេងត្រូវការពេលទំនេរខ្លះ និងត្រូវការធ្វើឱ្យធូរស្រាល ចំពោះបន្ទុកដែលមាន។
- ចូរអ្នកបន្តរក្សាឱ្យបានជាប់នូវចង្វាក់ សំរាប់ធ្វើការប្រមូលគំនិត។ ពួកគេនឹងធ្វើការបានយ៉ាងល្អនៅ ពេលដែលអ្នកដាក់សម្ពាធឱ្យពួកគេឆ្លើយតប។ ចូរប្រើសំណួរខ្លីហើយសួរទៅសមាជិកម្នាក់ៗ។ អ្នកត្រូវតែប្រាកដថា អ្នកបានពាក់ព័ន្ធអ្នករាល់គ្នា ហើយចង្អុលបង្ហាញសំណួរទៅកាន់អ្នកទាំងនោះ ដែលជាធម្មតាមានភាពរួញរាច្រើន។
- ចូរអ្នកកុំបណ្តោយឱ្យការពិភាក្សា មានភាពសង្ស័យធ្ងន់ និងស្រែក ដាក់គ្នា ព្រោះថាមានសមាជិកខ្លះ អាចប្រើលំហាត់ ជាលេសដើម្បី បញ្ចេញរឿងខឹងសម្បារ ឬធ្វើជារឿងកំប្លែង។ ការប្រមូលគំនិតនេះ គឺមិនគួរកាត់បន្ថយភាពហ្មត់ចត់ និងជំរៅបញ្ហារបស់កុមារពលកម្មទេ។ ចូរអ្នកគ្រប់គ្រងក្រុមពិភាក្សាឱ្យបាន។
- ចូរអ្នកកុំបណ្តោយម៉ោងរៀនពីការប្រមូលគំនិតបន្តអូសបន្លាយវែងពេកព្រោះវានឹងធ្វើឱ្យក្រុមពិភាក្សាមានការធុញទ្រាន់ និងដើរចេញពីការពិភាក្សា ប្រសិនបើអ្នកមិនអធ្យាស្រ័យគ្នាទេ។
- ចូរអ្នកធ្វើការត្រួតពិនិត្យទៅលើក្រុមពិភាក្សា ហើយត្រូវតែប្រាកដថាអ្នករាល់គ្នាចូលរួមប្រឹក្សា និងបញ្ចេញគំនិតទៅក្នុងលំហាត់ផ្សេងៗគ្នា
- ចូរអ្នកប្រើពេលសំរាប់សង្ខេបឱ្យបានសមរម្យ និងចូរអនុញ្ញាតិឱ្យពួកគេបញ្ចេញ ទស្សនៈផ្ទាល់ខ្លួនរបស់គេដោយបើកចំហរ និងដោយសេរី។ ចូរអ្នកទុកពេលខ្លះដើម្បីធ្វើការសំរាកផង។

ប្រសិនបើអ្នកបន្តការពិភាក្សាចុងក្រោយបន្ទាប់ពីលំហាត់នៃការប្រមូលគំនិតនោះ ចូរអ្នកប្រើប្រាស់លំហាត់ នេះជាប្រភេទ "បន្ធូរបន្ថយការតានតឹង"ដើម្បីឱ្យអ្នករាល់គ្នាបានសំរាក និងមានថាមពលមកវិញ។ ចូរអ្នកចាប់ផ្តើមដោយធ្វើជាការពិភាក្សាទូទៅមួយ។ ដោយឱ្យពួកគេបញ្ចេញដោយខ្លួនរបស់គេផ្ទាល់ទៅលើអ្វីមួយ។ ការបញ្ចេញគំនិតអាចមិនមានការពាក់ព័ន្ធទៅនឹងកុមារពលកម្មក៏បានដែរ។ ព្រោះថាកុមារពលកម្មវានឹងនៅជាប្រធានបទដ៏ចំបងដដែល។

នៅពេលដែលពួកគេត្រឡប់មកកាន់ប្រធានបទវិញ ហើយអ្នកមើលឃើញថា ពួកគេកំពុងតែយកចិត្តទុកដាក់ "ខ្ពស់" នៅក្នុងការប្រមូលគំនិតហើយនោះ ចូរអ្នកណែនាំការពិភាក្សាបែបហ្មត់ចត់ច្រើនឡើងទៅលើបញ្ហាប្រែប្រួលដែលកើតមាននៅក្នុងពិភពលោកយើងនេះ។ ចូរពន្យល់អំពីការផ្លាស់ប្តូរនោះ ដោយចាប់ផ្តើមពីការចង់ឱ្យមានការផ្លាស់ប្តូររបស់មនុស្សជាតិដែលស្ថិតនៅក្នុងសហគមន៍ទាំងអស់ និងសង្គម។ បំណងប្រាថ្នាចង់ឱ្យមានការផ្លាស់ប្តូរត្រូវធ្វើឱ្យមានឆន្ទៈមួយដើម្បីចាត់វិធានការ ហើយក្រោយមកធ្វើសកម្មភាពផ្ទាល់តែម្តង។ ការផ្លាស់ប្តូរកើតមានឡើងនៅពេលដែលមនុស្សជាតិមានតម្រូវការផ្លាស់ប្តូរកើតមានឡើងនៅពេលដែលមនុស្សភាគច្រើនអំពាវនាវដល់មេដឹកនាំសហគមន៍របស់គេ អ្នកនយោបាយរបស់គេ រដ្ឋាភិបាលរបស់គេភ្នាក់ងារតំបន់ និងអន្តរជាតិដោយទទូចសុំឱ្យមានការផ្លាស់ប្តូរ។ ហើយការផ្លាស់ប្តូរកើតឡើងនៅពេលដែលការជួយ និងគាំទ្រត្រូវបានគេចុះបញ្ជីពីសហគមន៍ និងអង្គការសង្គមស៊ីវិល អង្គការសប្បុរសធម៌ សហជីពពាណិជ្ជកម្ម សប្បុរសជនជាដើម។ វាពិតជាការត្រូវការ ពេលវេលាដើម្បីធ្វើការជំរុញលើកទឹកចិត្ត ការតាំងចិត្ត និងឆន្ទៈ ដើម្បីចាត់វិធានការ។

ការផ្លាស់ប្តូរទាំងអស់នៅក្នុងសង្គមបានចាប់ផ្តើមកើតឡើងនៅកន្លែងណាមួយនៅក្នុងពិភពលោកយើងនេះ។ គឺវាអាចចាប់ផ្តើមជាមួយមនុស្សវ័យក្មេង មានឧទាហរណ៍ជាច្រើនកើតឡើងក្នុងប្រវត្តិសាស្ត្រ ដូចនេះពួកគេគួរតែយល់ដឹងនូវអំណាចដែលកើតឡើងពីការប្រមូលផ្តុំ ដែលពួកគេមាន។

## ការពិភាក្សាបញ្ចប់

*បង្រៀនមួយពេល*



កិច្ចប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើងរួចរាល់យ៉ាងប្រសើរក្នុងការគោរពនូវកុមារពលកម្ម។ កិច្ចប្រឹងប្រែងនេះត្រូវការចាំបាច់នូវការគាំទ្រពីមនុស្សវ័យក្មេងទូទាំងពិភពលោក។ ការបរិច្ចាករបស់ពួកគេគឺមានសារៈសំខាន់ដូចគ្នានឹងជនទាំងឡាយដែលមាននៅក្នុងសង្គម។ វាកាន់តែជួយច្រើនថែមទៀត ដោយសារតែពួកគេជាអ្នកដែលមានអាយុស្របាលគ្នា និងកុមារពលកម្ម។

បញ្ចប់នូវកំណត់ចំណាំជាវិជ្ជមានដូចដែលបានពង្រឹងនូវការយល់ដឹង គឺជាជំហានមួយឆ្ពោះទៅមុខនៅក្នុង យុទ្ធនាការ ដើម្បីបំបាត់នូវពលកម្មកុមារ។ ពួកគេបានផ្តល់ជីវិតឱ្យទៅរូបភាព ដោយរូបភាពនោះនឹងនៅជាមួយពួកគេជារៀងរហូត។ ជាការពិតណាស់ប្រសិនបើអ្នកនិងក្រុមរបស់អ្នកបន្តជាមួយមេរៀននៅក្នុងម៉ូឌុលផ្សេងទៀតរូបភាពនេះនិងមានជីវិតយ៉ាងពិតប្រាកដ។ ចូរអ្នកបង្កើននូវការចង់ដឹង ចង់ឮពីធម្មជាតិរបស់ពួកគេដើម្បីឱ្យពួកគេដឹងអំពីសភាពការណ៍នេះ និងដើម្បីឱ្យពួកគេបង្កើននូវការតាំងចិត្តរបស់គេ និងការលើកទឹកចិត្ត ដើម្បីឃើញនូវអ្វីដែលកើតឡើងបន្ទាប់។

## ការវាយតម្លៃ និងសកម្មភាពបន្ត



ស្របគ្នាជាមួយលទ្ធផលជាក់លាក់នៃម៉ូឌុលនេះ មានអាំងឌីកាទ័រពីអារម្មណ៍ និង ចិត្តសាស្ត្រដែលនឹងជួយឱ្យធ្វើការវាយតំលៃបានលើផលប៉ះពាល់របស់វាបាន។

លទ្ធផលជាក់ស្តែងនៃសកម្មភាពទីមួយនឹងជាសំណុំឯកសារស្តីពីកុមារពលកម្ម ក្រុមនីមួយៗបង្កើតនូវសំណុំ ឯកសាររូបភាពផ្ទាល់ខ្លួនរបស់គេទៅលើប្រធានបទកុមារ។ ការចង្អុលបង្ហាញពីគំរិតនៃការសំរេចបាននៅក្នុងការរៀនមេរៀននេះ និងជាសំណុំឯកសារ និងកំណត់សរុប លំអិត។ ទាំងនេះនឹងចង្អុលបង្ហាញពីអ្វីដែលមនុស្សវ័យក្មេងនៅក្នុងក្រុម បានយកកុមារនេះមក " ចិញ្ចឹម "។ សំណុំឯកសារដែលមានលក្ខណៈ ច្នៃប្រឌិត និងស្រមើស្រមៃ និងមានការពណ៌នាលំអិតច្រើន គឺកាន់តែធ្វើឱ្យមនុស្សវ័យក្មេងទាំងនេះនឹងយកលំហាត់នេះជាប់នៅក្នុងចិត្ត ហើយយកកុមារដែលស្ថិតនៅក្រោមស្លាបការពាររបស់ខ្លួន។

ពុំមានអ្វីដែលជាក់ស្តែងពិតប្រាកដ ត្រូវបានគេបង្កើតនៅក្នុងសកម្មភាពទី ២។ អាំងឌីកាទ័រចំបងនេះដែលអ្នកអាចវាយតំលៃនូវផលប៉ះពាល់របស់វាគឺគំរិតនៃការចូលរួមរបស់ក្រុមនៅក្នុងការពិភាក្សា និងជាពិសេសលើម៉ោងរៀនពីការប្រមូលគំនិត។ អ្នកនឹងកត់ចំណាំឃើញ ថា ឯកសារយោងត្រូវបានគេបង្កើតឡើងទៅតាមរបៀបដែលសមាជិក នៅក្នុងក្រុមពិភាក្សារបស់អ្នកបានកសាងសំណុំឯកសារកុមារពលកម្ម។ ទាំងនេះគឺអាំងឌីកាទ័រដ៏សំខាន់ ចំពោះគំរិតនៃផលប៉ះពាល់នៃម៉ូឌុលនេះមានចំពោះមនុស្សវ័យក្មេងទាំងនេះ។

ម៉ូឌុលនេះគឺជាការតភ្ជាប់រវាងការបង្កើនការយល់ដឹង និង លក្ខណៈផ្ទាល់ខ្លួនរបស់កុមារពលកម្ម។ វាត្រូវបានរៀបចំ ដើម្បីឆ្ពោះទៅហួសពីការយល់ដឹងថា កុមារពលកម្មគឺជាបញ្ហាយល់ដឹងនូវអ្វីដែល ពាក់ព័ន្ធនិងកុមារតូច ហើយជាមនុស្សជាតិពិតប្រាកដដែលគេចេះ ដើរចេះនិយាយចេះមានអារម្មណ៍ និងចេះមានការឈឺចាប់។ ម៉ូឌុលនេះគឺមានលក្ខណៈធំទូលំទូលាយណាស់ ហើយក៏មានផលប៉ះពាល់ដ៏មានឥទ្ធិពល ដល់ អ្នកដែល

សិក្សាសៀវភៅនេះ។ នៅក្នុងសង្គមជាច្រើន ការរំលោភសិទ្ធិមនុស្សត្រូវបានគេគិតថា ជាអ្វីដែលបានកើតឡើងចំពោះអ្នកដទៃផ្សេង នៅក្នុងបណ្តាប្រទេសផ្សេងគ្នា ឬនៅតំបន់ផ្សេងៗគ្នា។ យើងអាចមិននៅផ្សារភ្ជាប់ជាមួយអ្វីដែលបានកើតនៅគ្រប់ទីកន្លែងក្នុងពិភពលោករបស់យើងប្រសិនបើយើងចង់ ធ្វើនោះ។ នៅក្នុងម៉ូឌុលនេះ គឺជាអ្វីមួយដែលគួរតែមានការចាប់ផ្តើមផ្លាស់ប្តូរឥរិយាបថ ដែលមនុស្សវ័យក្មេងបានមានអារម្មណ៍ ចំពោះបញ្ហាកុមារពលកម្ម។ ឥឡូវនេះកុមារពលកម្មបានលេចចេញជាមុខមាត់ និងមានជីវិតដែលមនុស្សវ័យក្មេងបានដក់ជាប់ក្នុងអារម្មណ៍ ហើយពួកគេឥឡូវនេះនឹងចង់ធ្វើអ្វីមួយដល់ IPEC ក្នុងកិច្ចប្រឹងប្រែងដែល IPEC បានលើកឡើង ពីព្រោះពួកគេនឹងមានអារម្មណ៍ផ្តោតទៅសមាជិក " ថ្មី " របស់ក្រុមពួកគេ វាគឺជារូបភាពទាំងឡាយដែលពួកគេបានផ្តោតអារម្មណ៍ នៅក្នុងម៉ូឌុលនេះហើយបានក្លាយមកជាមនុស្ស និងជាសមាជិកដែលមានអត្តសញ្ញាណមួយរបស់ក្រុម។

នៅពេលដែលឃើញថា ម៉ូឌុលនេះចង់ទៅប្រកបដោយការពេញចិត្តនោះ ចូរអ្នកបន្តទៅកាន់ម៉ូឌុលថ្មីមួយទៀត។ យើងសូមផ្តល់ជាយោបល់ដល់អ្នកថា ម៉ូឌុលបន្ទាប់ គឺអ្នកត្រូវបន្តបង្រៀនជាមួយរូបភាពរបស់កុមារពលកម្មទាំងឡាយដែលក្រុមពិភាក្សារបស់អ្នកបានស្គាល់ និងយកចិត្តទុកដាក់។ ជាឧទាហរណ៍នៅក្នុងម៉ូឌុលដែលនិយាយពីការសំដែងនោះ ការទទួលខុសត្រូវរបស់មនុស្សវ័យក្មេងនឹងផ្តល់ជីវិតរបស់បណ្តាតួអង្គទាំងឡាយនៅក្នុងរូបភាពដែលគេបានបង្កើតដោយសំដែងចេញពីជីវិតរស់នៅរបស់ពួកគេ។

## គណៈកម្មការដឹកនាំ និងគ្រប់គ្រង

| | |
|---|---|
| ១_លោក ភុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គួលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការរៀបរៀង និងចងក្រង

| | |
|---|---|
| ១_លោក ភុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គួលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោក ឡង់ សុផាត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការបកប្រែ

| | | | |
|---|---|---|---|
| ១_លោកស្រី កង សុថាវី | ប្រធានការិយាល័យក្រោយអក្ខរកម្ម | ២_លោកស្រី តុប ប៊ុនថា | ប្រធានការិយាល័យអក្ខរកម្ម |
| ៣_លោក ញ៉ែម ភីណារ៉េត | អនុប្រធានការិយាល័យរដ្ឋបាល | ៤_លោក តេះ ដារី | អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ |
| ៥_លោក ជិន និវត្តន៍ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_លោកស្រី ទី វត្តី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោក ភូ យន់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៨_លោកស្រី ស៊្រុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៩_កញ្ញា អ៊ុក ធារី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១០_លោក គ្រួច លក្ខិណា | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១១_លោកស្រី លី ខេង | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការផ្ទៀងផ្ទាត់

| | | | |
|---|---|---|---|
| ១_លោក សំ ចាន់ទិត | អនុប្រធានការិយាល័យអក្ខរកម្ម | ២_លោក រង់ សូវង្ស | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក ឈុំ ច័ន្ទមុនីរ៉េត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៤_លោកស្រី ជា សុផល | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក កែវ គង់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_កញ្ញា ម៉ៅ ផល្លី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោកស្រី ស៊្រុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

| | |
|---|---|
| ១_លោក ឈិន វិត | ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ២_លោក ពេជ្រ និពន្ធ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៣_លោកស្រី ឈុំ សោភ័ណ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៤_លោកស្រី សួច ផាន់ណា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៥_លោកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៦_កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |

# បញ្ឈប់ពលកម្មកុមារ

# Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**


**សូមថ្លែងអំណរគុណ**

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាឆីរ ប៉ូល យូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវីរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់ (TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗ និងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្គ្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦



នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ : (០២៣) ៧២៦ ៥៦៣ / ២១៩ ២៥៨**

**Email : nfe@camnet.com.kh**



ISBN-9789995088217